# 「កន្លែងទាំង5」 ដែលមានហានិភ័យឆ្លងខ្ពស់

## កន្លែងទី① កន្លែងពិធីជប់លៀងមានផឹកស្រាជុំគ្នាជាដើម

- ស្របពេលដែលអារម្មណ៍កើនឡើងដោយឥទ្ធិពលនៃជាតិអាល់កុល ស្មារតីប្រុងប្រយ័ត្ន ក៏នឹងធ្លាក់ចុះ។ ម្យ៉ាងទៀត វិញ្ញាណស្តាប់ក៏នឹងធ្លាក់ចុះ ធ្វើឲ្យសម្លេងងាយនឹងឡើងធំ។
- ជាពិសេស នៅក្នុងលំហចង្អៀតដែលខណ្ឌដោយជញ្ជាំង នៅរយៈពេលយូរ និងមានមនុស្សច្រើន ធ្វើឲ្យហានិភ័យនៃការឆ្លងនឹងកាន់តែខ្ពស់។
- ្យ៉ាងទៀត ការផឹកវិលជុំនិងការប្រើប្រាស់ចង្កឹះរួមគ្នាជាដើម ក៏ធ្វើឲ្យហានិភ័យនៃការឆ្លងកើនឡើង។



## កន្លែងទី② ការផឹកស៊ីមានមនុស្សច្រើន ឬរយៈពេលយូរ

- ការផឹកស៊ីរយៈពេលយូរ ការផឹកស៊ីទទួលភ្ញៀវ និងការផឹកស៊ីពីកន្លែងមួយទៅកន្លែងមួយ មានហានិភ័យឆ្លងខ្ពស់ជាង បើប្រៀបធៀបជាមួយការបរិភោគអាហាររយៈពេលខ្លី។
- ករណីបរិភោគអាហារមានមនុស្សច្រើន ដូចជាលើសពី៥នាក់ឡើង តំណក់ទឹកមាត់ងាយខ្ទាតចេញដោយសារត្រូវប្រើសម្លេងខ្លាំង ជាហេតុធ្វើឲ្យហានិភ័យឆ្លងកើនឡើង។



## កន្លែងទី③ ការសន្ទនាដោយមិនប្រើម៉ាស់

- ការសន្ទនានៅជិតគ្នាដោយមិនប្រើម៉ាស់ ហានិភ័យឆ្លងដោយការខ្ទាតទឹកមាត់ ឬការខ្ទាតសារធាតុមីក្រូនឹងកើនឡើង។
- ជាឧទាហរណ៍នៃការឆ្លងដោយគ្មានម៉ាស់ ត្រូវបានកត់សម្គាល់ឃើញកើតមានរួចមកហើយ នៅកន្លែងខារ៉ាអូខេពេលរសៀល។
- នៅក្នុងរថយន្តពេលធ្វើដំណើរដោយរថយន្ត ឬរថយន្តក្រុងក៏ចាំបាច់ត្រូវប្រុងប្រយ័ត្ន។





## កន្លែងទី④ ការរស់នៅរួមគ្នានៅកន្លែងចង្អៀត

- ពេលរស់នៅរួមគ្នានៅកន្លែងចង្អៀត ដោយសារតែលំហបិតជិត(បន្ទប់) ត្រូវប្រើរួមគ្នារយៈពេលយូរ ហានិភ័យឆ្លងនឹងកើនឡើង។
- មានការរាយការណ៍អំពីករណីសង្ស័យមានការឆ្លងនៅកន្លែងប្រើរួមគ្នា ដូចជាបន្ទប់អន្តេវាសិកដ្ឋាន ឬបង្គន់ជាដើម។





## កន្លែងទី⑤ ការផ្លាស់ប្តូរកន្លែង

- ពេលដល់ម៉ោងសម្រាកនៅពេលធ្វើការងារ យើងតែងផ្លាស់ប្តូរកន្លែងដើម្បីជាការបន្ធូរអារម្មណ៍ ឬការផ្លាស់ប្តូរបរិយាកាសបែបនេះ អាចធ្វើឲ្យហានិភ័យឆ្លងកើនឡើង។
- មានការរាយការណ៍អំពីករណីសង្ស័យមានការឆ្លងនៅតាមបន្ទប់សម្រាក បន្ទប់ជក់បារី និងបន្ទប់ផ្លាស់ប្តូរខោអាវជាដើម។





クメール語